**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
**លេខ:០១៤/០៨ របក.អគគ**

# របាយការណ៍ ស្តីពី សកម្មភាពការងារប្រចាំ ត្រីមាស ឆ្នាំ ២០០៨ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងទិសដៅសម្រាប់អនុវត្តបន្ត

ចាប់ពីខែ មករា ដល់ខែមីនា ឆ្នាំ ២០០៨ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមាន អង្គភាពគ្រប់គ្រងគម្រោង ជាអង្គភាពប្រតិបត្តិ បានដំណើរការងាររបស់ខ្លួនស្របតាមបេសកកម្ម ដែលបានកំណត់ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូច ខាងក្រោម ៖

## ១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

### ក. ការងាររដ្ឋបាល

-ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំការងារបច្ចេកទេសប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី ១១ ខែមករា ឆ្នាំ២០០៨

-លិខិតស្នើបញ្ជូនមន្ត្រី ៣ រូប ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលស្តីពី “Training Program for Young Leader for Asian Countries for Fiscal Year 2007” ដែលនឹងប្រព្រឹត្តទៅ ចាប់ពីថ្ងៃទី២៥ ខែកុម្ភៈ ដល់ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៨ នៅប្រទេសជប៉ុន

-ផ្ញើលិខិតអញ្ជើញចូលរួមប្រជុំការងារបច្ចេកទេសប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការបន្ត ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី ១៨ ខែមករា ឆ្នាំ២០០៨

-លិខិតស្នើសុំការផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជ-អាជ្ញានៃព្រះរាជាណាចក្រកម្ពុជា

-ស្នើសុំធ្វើលិខិតឆ្លងដែនផ្លូវការ ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលស្តីពី “Training Program for Young Leader for Asian Countries for Fiscal Year 2007” នៅប្រទេសជប៉ុន សម្រាប់មន្ត្រីក្រុមគម្រោងកំណែទម្រង់ច្បាប់

-លិខិតអញ្ជើញចូលរួមប្រជុំអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សា កំណែ ទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០០៨

-ផ្ញើដីកាអមនៃរបាយការណ៍ស្តីពីកិច្ចប្រជុំលើកទី ១ និងលើកទី ២ អំពីការរៀបចំប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ ជូនក្រសួង ស្ថាប័ន និងសមាជិកពាក់ព័ន្ធ

-ផ្ញើដីកាអម នៃឯកសារពាក់ព័ន្ធមួយចំនួនសម្រាប់កិច្ចប្រជុំអង្គភាពសម្របសម្រួល អចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងតុលាការ ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០៨ ជូនសមាជិកពាក់ព័ន្ធ

-លិខិតអញ្ជើញចូលរួមប្រជុំក្រុមការងារបច្ចេកទេសតុលាការគំរូ ដើម្បីអនុម័តសេចក្តីព្រាងការវិភាគលើ លក្ខណៈវិនិច្ឆ័យ ស្តង់ដារ និងសំណួរទាក់ទងនឹងតុលាការគំរូកម្ពុជា ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០០៨ នៅសណ្ឋាគារសាន់វេ

-លិខិតអញ្ជើញចូលរួមប្រជុំអនុក្រុមទី ៤ នៃក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលា ការ ដែលនឹងប្រព្រឹត្តទៅ នៅថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០០៨

-លិខិតអញ្ជើញចូលរួមប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ ដែលនឹង ប្រព្រឹត្តទៅ នៅថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០០៨។

-លិខិតស្នើបញ្ជូនសាលដីការដ្ឋប្បវេណី និងព្រហ្មទណ្ឌប្រចាំត្រីមាសទី ១ និងត្រីមាសទី ២ ឆ្នាំ២០០៧ របស់តុលាការកំពូលសម្រាប់ចងក្រងជាព្រឹត្តិបត្រ័សាលដីកា

-លិខិតអញ្ជើញចូលរួមសិក្ខាសាលា ស្តីពីកម្មវិធីផ្លាស់ប្តូរយោបល់ជាមួយភ្នាក់ងារអនុវត្តនានា និងសង្គមស៊ីវិល នៅតាមបណ្តាខេត្ត-ក្រុងទាំងឡាយ ដើម្បីពិចារណារកវិធីសាស្ត្រដែលល្អប្រសើរ សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅសណ្ឋាគារសាន់វេ នៅថ្ងៃពុធ ទី២៦ ខែមីនា ឆ្នាំ២០០៨ វេលាម៉ោង ៧ៈ៣០ ព្រឹក ដល់ ម៉ោង ១៧ៈ00 ល្ងាច

-លិខិតស្នើបញ្ជូនលោក ឆុង ហួត ឱ្យទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ នៅទីក្រុងម៉ានីលប្រទេសហ្វីលីពីន

-លិខិតស្នើរៀបចំសិក្ខាសាលា ស្តីពីកម្មវិធីផ្លាស់ប្តូរយោបល់ជាមួយភ្នាក់ងារអនុវត្តនានា និងសង្គមស៊ីវិល នៅតាមបណ្តាខេត្ត លើការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តបាត់ដំបង និងក្រុងព្រះសីហនុ។

-លិខិតអញ្ជើញចូលរួមប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ (TWG/LJR)នៅថ្ងៃទី ៧ ខែមេសា ឆ្នាំ២០០៨ វេលាម៉ោង ១៤ៈ៣០ រសៀល។

**ខ. ការងារកំណែទម្រង់**

-រៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលា ការ នៅថ្ងៃទី ១១ ខែមករា ឆ្នាំ២០០៨

-រៀបចំកិច្ចប្រជុំការងារបច្ចេកទេសប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការបន្ត នៅថ្ងៃទី ១៨ ខែមករា ឆ្នាំ២០០៨

-ចុះជួបក្រសួងយុត្តិធម៌ នៅថ្ងៃទី ១៤ ខែមករា ឆ្នាំ២០០៨ និងក្រសួងមហាផ្ទៃ នៅថ្ងៃទី ១៥ ខែមករា ឆ្នាំ២០០៨ ដើម្បីជម្រាបជូនពីការរៀបចំប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការ

-ចូលរួមប្រជុំក្រុមប្រឹក្សាគ្រប់គ្រងគម្រោង CCJAPIII នៅសណ្ឋាគារ Himawari នៅថ្ងៃទី ១៦ ខែមករា ឆ្នាំ២០០៨។

-ប្រជុំអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០០៨

-ប្រជុំជាមួយអ្នកឯកទេសអន្តរជាតិពាក់ព័ន្ធនឹងគម្រោងតុលាការគំរូ នៅថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០០៨

-ប្រជុំក្រុមការងារបច្ចេកទេសតុលាការគំរូ ដើម្បីអនុម័តសេចក្តីព្រាងការវិភាគលើលក្ខណៈវិនិច្ឆ័យ ស្តង់ដារ និងសំណួរទាក់ទងនឹងតុលាការគំរូកម្ពុជា នៅថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០០៨ នៅសណ្ឋាគារសាន់វេ

-ប្រជុំអនុក្រុមទី ៤ នៃក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ២០០៨

-ប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃ ទី២៥ ខែកុម្ភៈ ឆ្នាំ២០០៨

-ប្រជុំពិភាក្សាជាចុងក្រោយនូវរបាយការណ៍ស្តីពីការរៀបចំប្រព័ន្ធទិន្នន័យ នៅថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០០៨

-ធ្វើការបណ្តុះបណ្តាលការធ្វើផែនការ និងការគ្រប់គ្រង នៅក្រសួងយុត្តិធម៌ នៅថ្ងៃទី ១២-១៣ ខែកុម្ភៈ ឆ្នាំ២០០៨ និងថ្ងៃទី ១៩-២០ ខែកុម្ភៈ ឆ្នាំ២០០៨។

-ទទួលជួបក្រុមការងាររបស់កម្មវិធី CCJAPIII ស្វែងយល់ពីការងារសម្របសម្រួល និងយន្តការ ប្រមូលទិន្នន័យ

-ចូលរួមពិនិត្យសេចក្តីព្រាងផែនការប្រចាំឆ្នាំ ២០០៨-២០០៩ របស់ CCJAPIII

-រៀបចំសិក្ខាសាលាស្តីពីកម្មវិធីផ្លាស់ប្តូរយោបល់ជាមួយភ្នាក់ងារអនុវត្តនានា និងសង្គម-ស៊ីវិល នៅតាមបណ្តាខេត្ត-ក្រុងទាំងឡាយ ដើម្បីពិចារណារកវិធីសាស្ត្រដែលល្អប្រសើរ សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅសណ្ឋាគារសាន់វេ នៅថ្ងៃពុធ ទី២៦ ខែមីនា ឆ្នាំ២០០៨ វេលាម៉ោង ៧:៣០ ព្រឹក ដល់ ម៉ោង ១៧:០០ ល្ងាច

-ជួបជាមួយអ្នកឯកទេសមកពី EU ដើម្បីពិភាក្សាលើលទ្ធភាពរបស់ EU ក្នុងការជួយឧបត្ថម្ភដល់កំណែទម្រង់ច្បាប់ និងតុលាការ

-ពិភាក្សារៀបចំជាមួយ UNDP បន្តជំនួយដល់គម្រោងប្រមូលទិន្នន័យ ការបណ្តុះបណ្តាលសិទ្ធិមនុស្ស

-ប្រជុំក្រុមគម្រោង PMUរៀបចំប្រព័ន្ធសូចនាករតាមដានការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និង តុលាការ

-ជួបជាមួយប្រធាន EWMI ដើម្បីពិភាក្សាអំពីលទ្ធភាពបន្តកិច្ចសហការទៅអនាគត

-រៀបចំតារាងភាពជឿនលឿននៃការអនុវត្តផែនការជាតិជូនក្រសួងផែនការ

-ចូលរួមប្រជុំ GDCC នៅថ្ងៃអង្គារ ទី៤ ខែមីនា ឆ្នាំ២០០៨។

**គ. ផ្សេងៗ**

-ទទួលជួបក្រុមការងារ USAID ស្វែងយល់ពីកំណែទម្រង់ច្បាប់ និងតុលាការ នៅថ្ងៃទី ២២ ខែមករា ឆ្នាំ២០០៨

-បញ្ជូនមន្ត្រីអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ចូលរួមវគ្គ បណ្តុះបណ្តាលស្តីពី “Training Program for Young Leader for Asian Countries for Fiscal Year 2007”” នៅប្រទេសជប៉ុន ចាប់ពីថ្ងៃទី ២៥ ខែកុម្ភៈ រហូតដល់ថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០០៨

-ចូលរួមក្នុងសិក្ខាសាលាបូកសរុបលទ្ធផលការងារពន្ធនាគារ នៅថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ២០០៨

-ចូលរួមពិភាក្សាបញ្ហាមូលនិធិបត់បែន នៅលេខាធិការដ្ឋាន CCJAPIII នៅថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០០៨

-ចូលរួមសិក្ខាសាលាអំពីយុត្តិធម៌កុមារ រៀបចំដោយក្រសួងយុត្តិធម៌ នៅសណ្ឋាគារ សាន់វេ នៅថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០០៨

-ចូលរួមប្រជុំពិនិត្យផែនការប្រចាំឆ្នាំ ២០០៨-២០០៩ របស់ CCJAPIII នៅថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ២០០៨។

-ចូលរួមប្រជុំពិនិត្យរបាយការណ៍តាមក្រសួង សម្រាប់សន្និសីទស្តីពីលទ្ធផលការងាររបស់រដ្ឋាភិបាល ២០០៤-២០០៨ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៨

-ចូលរួមប្រជុំជាមួយក្រុមអគ្គលេខាធិការដ្ឋានកំណែទម្រង់រដ្ឋបាល ពិនិត្យរបាយការណ៍ស្តីពីការអនុវត្តកម្មវិធី GAPII

-ចូលរួមប្រជុំអន្តរក្រសួងផ្សេងៗ។

២-សន្និដ្ឋាន

ចាប់ពីខែមករា ដល់ខែមីនា ឆ្នាំ ២០០៨ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានរៀបចំប្រជុំការងារបច្ចេកទេសប្រព័ន្ធសូចនាករ និងការតាមដានកំណែទម្រង់ច្បាប់ និងតុលាការចំនួនពីរលើក ដោយបានឯកភាពគ្នាទៅលើគោលការណ៍ចំបងៗ សម្រាប់រៀបចំសូចនាករ និងការតាមដាន និងបានរៀបចំប្រជុំអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងតុលាការ ដើម្បីពិនិត្យរបាយការណ៍ប្រចាំឆ្នាំ២០០៧ និងទិសដៅសម្រាប់ឆ្នាំ២០០៨ និងបានរៀបចំប្រជុំបន្តក្រុមការងារបច្ចេកទេសតុលាការគំរូ។ បន្ថែមទៅលើការងារខាងលើនេះ អង្គភាពគ្រប់គ្រងគម្រោង បានអនុវត្តនូវការងារសំខាន់ ២ គឺរៀបចំសិក្ខាសាលាផ្លាស់ប្តូរយោបល់ជាមួយស្ថាប័នអនុវត្ត និងសង្គមស៊ីវិលលើការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ និងការប្រជុំផ្ទៃក្នុង PMU ដើម្បីរៀបចំតារាងសូចនាករសម្រាប់តាមដានកំណែទម្រង់ ច្បាប់ និងតុលាការ។

## ៣-ទិសដៅអនុវត្តក្នុងត្រីមាសបន្ត

-បន្តជម្រុញការអនុវត្តគម្រោងតុលាការគំរូ ជាពិសេសរៀបចំកិច្ចប្រជុំក្រុមការងារជាន់ខ្ពស់គម្រោង តុលាការគំរូ

-បន្តជម្រុញការអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដាន

-បន្តការពិភាក្សា ជាមួយ ្ណាឧភ លើការឧបត្ថម្ភបន្តលើគម្រោងរៀបចំប្រព័ន្ធទិន្នន័យ

-រៀបចំសិក្ខាសាលាស្តីពីកម្មវិធីផ្លាស់ប្តូរយោបល់ជាមួយស្ថាប័នអនុវត្ត និងសង្គមស៊ីវិលលើការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ នៅតាមបណ្តាខេត្តមួយចំនួនទៀត ដូចជាខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តបាត់ដំបង និងក្រុងព្រះសីហនុ។

-ពិភាក្សាបន្តកិច្ចសហប្រតិបត្តិការជាមួយ DANIDA និង CCJAPIII ក្នុងការឧបត្ថម្ភកំណែទម្រង់ច្បាប់ និងតុលាការសម្រាប់ ២ ឆ្នាំទៅមុខទៀត។

-ផ្តួចផ្តើមពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍ខ្លះ ដូចជា USAID, EU, GTZ ដើម្បីស្វែងរកជំនួយបន្ថែមសម្រាប់អនុវត្តកម្មវិធីសកម្មភាពនៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ។

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ ២០០៨

អ្នកធ្វើរបាយការណ៍

ហ៊ីង សុកុល

បានឃើញ និងឯកភាព

នាយកអង្គភាពគ្រប់គ្រងគម្រោង

ស៊ុយ ម៉ុងលាង